FUND OUR SCHOOLS

FOR MORE INFORMATION VISIT
philasd.org/fundourschools

#FundOurSchools

**ឯកសារបណ្តាញសារព័ត៌មានសង្គម**

**ផែនការគាំទ្រយុទ្ធនាការ Fund Our Schools**

មណ្ឌលសិក្សាធិការនៃទីក្រុង Philadelphia បានបង្កើតឯកសារនេះឡើងដើម្បីជួយកែលម្អស្ថានភាពផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុធ្ងន់ធ្ងរដែលបណ្តាលមកពីជំងឺរាតត្បាតCOVID-19 ដែលនឹងកើតមានទៅលើកញ្ចប់ថវិការបស់មណ្ឌលសិក្សាធិការនៃទីក្រុង Philadelphia។ នៅក្នុងសៀវភៅណែនាំនេះ អ្នកនឹងទទួលបានព័ត៌មាន និងសារដែលបណែនាំពីយុទ្ធនាការ Fund Our Schools ដែលមានគោលបំណងផ្តល់ជូនអ្នកនូវការណែនាំ និងសារតារសម្រាប់ការប្រាស្រ័យទាក់ទងជាមួយមន្ត្រីដែលយើងបានបោះឆ្នោតជ្រើសរើស និងភាគីពាក់ព័ន្ធពីខាងក្រៅ។

ឯកសារនេះ ផ្តល់សារ និងរូបភាពក្រាហ្វិកនានាដើម្បីជួយ៖

- **ជំរុញឱ្យមានការទទួចស្នើសុំ និងមានការដឹងឮទៅដល់លោកអភិបាលក្រុង Wolf អ្នកតំណាងរដ្ឋ និងសមាជិកព្រឹទ្ធសភារដ្ឋរបស់អ្នកថាពួកគេមិនអាចកាត់ផ្តាច់ការផ្តល់មូលនិធិអប់រំនេះបានទេ**
- បរិយាយប្រាប់ពីគំនិតយោបល់ ក្នុងនាមជាពលរដ្ឋនៃទីក្រុង Pennsylvania មតិយោបល់របស់អ្នកមានសារៈសំខាន់ណាស់។
- ចូលរួមជាមួយនឹងអ្នកបង្កើតគោលនយោបាយនៅក្នុងការពិភាក្សាអំពីបញ្ហានានាដែលពាក់ព័ន្ធ មានដូចជា បញ្ហាដែលអ្នកជួបប្រទះនៅក្នុងសហគមន៍របស់អ្នកជាដើម
- ធានានូវការផ្តល់សារត្រឹមត្រូវថ្មីៗពីប្រភពដែលមានការជឿទុកចិត្ត។
- ចែករំលែកធនធាន

រាល់រូបភាពក្រាហ្វិក និងសារដែលបានណែនាំ មានផ្តល់ជូនសម្រាប់ប្រើប្រាស់នៅតាមប្រ៉ូហ្វាល់បណ្តាញព័ត៌មានសង្គម និងគេហទំព័រ។

សម្រាប់រូបភាពបន្ថែម និងខ្លឹមសារ #FundOurSchools អ្នកអាចចូលទៅកាន់ XXX របស់យើង។ សូមចាំថាត្រូវប្រើប្រាស់ #FundOurSchools នៅពេលបង្ហោះខ្លឹមសារដែលពាក់ព័ន្ធនឹងយុទ្ធនាការ Fund Our Schools ហើយថេកភ្ជាប់ទៅលោកអភិបាលក្រុង Wolf ក៏ដូចជាសមាជិកសភារដ្ឋរបស់អ្នកផងដែរ។

**ចម្លងអត្ថបទ**

## Hashtag៖

#FundOurSchools

**យុទ្ធវិធី៖**

1. ប្រើប្រាស់រូបភាពក្រាហ្វិកធម្មតាដើម្បីបង្កើតអារម្មណ៍រួមគ្នាជាផ្លូងមួយ
2. ប្រើប្រាស់បណ្តាញព័ត៌មានសង្គមធ្វើជាកន្លែងសម្រាប់ការបង្កើតកិច្ចសហប្រតិបត្តិការ និងការទទួចស្នើសុំ
3. ថេកភ្ជាប់មន្ត្រីដែលអ្នកបានបោះឆ្នោតជ្រើសរើសទៅក្នុងព័ត៌មានដែលអ្នកបង្ហោះ។ ចូលទៅកាន់គេហទំព័រនេះ៖ [https://live.cicerodata.com/](https://live.cicerodata.com/) ដើម្បីបង្ហាញឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នកតំណាងអ្នក។

| ភាសានៅក្នុងបណ្តាញសារព័ត៌មានសង្គម | | | |
|---|---|---|---|
| | INSTAGRAM | FACEBOOK | TWITTER |
| **បណ្តាញសារព័ត៌មានសង្គម<br>ការបង្ហោះព័ត៌មានគំរូ<br>(ទូទៅ)** | ✓ យើងមិនអាចអនុញ្ញាតឲ្យទីក្រុង Harrisburg កាត់ផ្តាច់ការផ្តល់មូលនិធិសម្រាប់ការអប់រំ ឬប្រើប្រាស់ការផ្តល់មូលនិធិសហព័ន្ធរបស់យើងដើម្បីបំពេញតាមកាតព្វកិច្ចរដ្ឋឡើយ។ ចូលទៅកាន់ philasd.org/fundourschools ដើម្បីស្វែងយល់ពីរបៀបដែលអ្នកអាចអនុវត្តវិធានការនៅថ្ងៃនេះ! #FundOurSchools<br><br>✓ កុំកាត់ផ្តាច់ការផ្តល់មូលនិធិសម្រាប់ការអប់រំ។ មណ្ឌលសិក្សាធិការនៃទីក្រុង Philadelphia កំពុងជួបប្រទះការខ្វះខាតចំណូលមួយចំនួនធំដែលកង្វះខាតនេះនឹងមានការកើតឡើងដល់ 1 ប៊ីលានដុល្លារនៅក្នុងរយៈពេលប្រាំឆ្នាំបន្ទាប់។ #FundOurSchools នៅពេលនេះ [ថេកមន្ត្រីដែលអ្នកបានបោះឆ្នោតជ្រើសរើស]<br><br>✓ មិនត្រូវរក្សាតុល្យភាពកញ្ចប់ថវិការដ្ឋ ជាថ្នូរទៅនឹងការបង់ខាតរបស់កូនចៅយើងនោះទេ។ ផ្តល់មូលនិធិក្នុងកម្រិតឆ្នាំសិក្សា 2019-2020។ #FundOurSchools [ថេកមន្ត្រីដែលអ្នកបានបោះឆ្នោតជ្រើសរើស]<br><br>✓ បញ្ចូលទៅឲ្យមណ្ឌលសិក្សាធិការនូវការផ្តល់មូលនិធិសហព័ន្ធរបស់ពួកគេដើម្បីជួយបង្ការការកាត់ផ្តាច់កញ្ចប់ថវិកា។ ច្បាប់ CARES Act របស់សហព័ន្ធ កញ្ចប់ជំនួយដែលសភាបានអនុម័តនៅក្នុងខែមេសា រួមបញ្ចូលនូវទឹកប្រាក់ច្រើនជាង 115 លានដុល្លារសម្រាប់សិស្ស និងសាលារៀននៅទីក្រុង Philadelphia។ **#FundOurSchools**<br><br>✓ វិបត្តិសេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺរាតត្បាត COVID-19 កំពុងតែប៉ះពាល់យ៉ាងខ្លាំងដល់ចំណូលពន្ធតាមមូលដ្ឋានរបស់មណ្ឌលសិក្សាធិការនៃទីក្រុង Philadelphia និងអាចមានលទ្ធភាពលុបចោលរាល់វឌ្ឍនភាពដែល SDP សម្រេចបានក្នុងរយៈពេលប្រាំពីរឆ្នាំចុងក្រោយនេះ។ **#FundOurSchools**<br><br>✓ DYK: ថវិកាតុល្យភាពដែលបានស្នើសុំរបស់មណ្ឌលសិក្សាធិការនៅពេលនេះ រួមមានការខ្វះខាតទឹកប្រាក់ 38 លានដុល្លារ ដែលចំនួននេះនឹងកើនឡើងដល់ 1 ប៊ីលានដុល្លារនៅត្រឹមឆ្នាំសិក្សា 2024-2025។ **#FundOurSchools** | | |

ស៊ុមរូបភាពលើបណ្តាញសង្គម FACEBOOK៖ បង្ហាញពីការគាំទ្ររបស់អ្នកក្នុងនាមជាអ្នកគាំទ្រ #FundOurSchools លើបណ្តាញសង្គម Facebook។ អាចរកមើលស៊ុមរូបភាពដោយការស្វែងរកនៅលើ #fundourschools នៅពេលអ្នកជ្រើសរើសស៊ុមរូបភាពប្រូហ្វាល់ថ្មីណាមួយ។